# ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ-ច្បាប់

## ក្រឹត្យ-ច្បាប់ លេខ ២៧ ក្រ.ច

### ស្តីពីការចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនជាបណ្តោះអាសន្ន ការដោះលែង ការឆែកឆេរលំនៅដ្ឋាន សម្ភារវត្ថុ និង លើខ្លួនបុគ្គល

## ក្រុមប្រឹក្សារដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៤ ក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**<u>សម្រេច</u>**

## ជំពូកទី១

### បទបញ្ញត្តិទូទៅ

**មាត្រា ១** ក្រឹត្យ -ច្បាប់នេះមានទិសដៅ ធ្វើអោយមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹង បទល្មើស ធានាសន្តិសុខសង្គម ពង្រឹងនីត្យានុកូលភាព ការពារទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព ទ្រព្យសម្បត្តិស្របច្បាប់ និង លំនៅដ្ឋានរបស់ប្រជាជន នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

**មាត្រា ២** ការរំលោភបំពានលើរូបកាយបុគ្គលណាមួយត្រូវហាមឃាត់ ។

-ជនណាក៏ដោយ មិនត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយខុសច្បាប់ ។

-ការធ្វើទារុណកម្មលើជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ជាបណ្តោះអាសន្ន ត្រូវហាមឃាត់ ។

-ការធ្វើទារុណកម្មលើជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ជាបណ្តោះអាសន្ន ដើម្បីបង្ខិតបង្ខំអោយឆ្លើយទទួលសារភាព ឬ ឆ្លើយខុសពីការពិតក្នុងពេលសួរចម្លើយ ត្រូវហាមឃាត់ ។

**មាត្រា ៣** ហាមដាច់ខាតមិនអោយមានការរំលោភទៅលើលំនៅដ្ឋានរបស់ប្រជាជន ។
ការឆែកឆេរលំនៅដ្ឋាន សម្ភារវត្ថុ និង លើខ្លួនបុគ្គល ត្រូវធ្វើអោយស្របនឹងបញ្ញត្តិនៃក្រឹត្យ- ច្បាប់នេះ ។

## ជំពូកទី២

## អំពីការចាប់ខ្លួន

**មាត្រា ៤** ការចាប់ខ្លួន និង ធ្វើទៅបាន

-ក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង

-ក្នុងករណីបន្ទាន់ ហើយមានភ័ស្តុតាង

-ក្នុងករណីមានដីកា សេចក្តីសម្រេចអោយចាប់ខ្លួន ឬ លិខិតប្រកាសឲ្យរកចាប់ខ្លួនពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៥** ជនប្រព្រឹត្តបទល្មើសជាក់ស្តែងគឺ

-ជនដែលគេឃើញទាន់កំពុងប្រព្រឹត្តបទល្មើស ឬ ទើបនឹងប្រព្រឹត្តបទល្មើសរួចភ្លាមៗ

-ជនប្រព្រឹត្តបទល្មើសដែលត្រូវគេស្រែកដេញប្រដាប់ចាប់ប្រភីង

-ជនដែលជាប់ឃុំ ហើយកំពុងរត់ចេញពីមន្ទីរឃុំឃាំង

**មាត្រា ៦** ក្នុងករណីជាបន្ទាន់ និង មានភ័ស្តុតាងមួយចំនួនអាចត្រូវចាប់ខ្លួនបាន ៖

-ជនណាដែលមានសាក្សី ឬ ជនរងគ្រោះបានស្គាល់ថាពិតជាបានប្រព្រឹត្តបទល្មើស

-ជនណាដែលគេឃើញមានភ័ស្តុតាង នៃបទល្មើសជាប់នឹងខ្លួន ឬ នៅក្នុងលំនៅដ្ឋាន

-ជនណាដែលត្រៀមគេចខ្លួន ឬបានគេចខ្លួន

-ជនណាដែលត្រៀមបំផ្លាញភ័ស្តុតាង ឬ កំពុងបំផ្លាញភ័ស្តុតាងក្លែងបន្លំភ័ស្តុតាង ស៊ីគ្រលំជាមួយគូកន ដើម្បីគេចផុតពីការផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៧** អាចនឹងចាប់ខ្លួនបានតែជនណាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងច្បាប់ហើយ ដែលត្រូវផ្តន្ទាទេសដាក់ពន្ធនាគារ ។

ហាមផ្តាច់មិនអោយចាប់ខ្លួន បើបទល្មើសមានប្រភេទជាបទល្មើសរដ្ឋប្បវេណី ឬ ជាបទល្មើសព្រហ្មទណ្ឌតូចតាច ។

**មាត្រា ៨** ហាមផ្តាច់មិនអោយចាប់ខ្លួនជនណា ដែលគ្រាន់តែមានពាក្យគេប្តឹងជាលាយល័ក្ខណ៍អក្សរ ឬ ប្តឹងដោយមាត់ទទេ គ្រាន់តែមានការសង្ស័យ ហើយគ្មានភ័ស្តុតាងគ្រប់គ្រាន់

ក្នុងករណីនេះចាំបាច់ត្រូវតែធ្វើអង្កេតស៊ើបសួរជាបឋម ដើម្បីប្រមូលភ័ស្តុតាង និង រកពិរុទ្ធភាពលើជនដែលត្រូវគេប្តឹង ។

**មាត្រា ៩** ក្រៅពីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង និង ក្រៅពីបទល្មើសព្រហ្មទណ្ឌ ប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខនយោបាយ ឬ សណ្តាប់ធ្នាប់សង្គម ការចាប់ខ្លួនចំពោះកម្មករ បុគ្គលិក យុទ្ធជន កម្មាភិបាល ដែលទទួលបៀវត្សពីរដ្ឋ អាចនឹងធ្វើទៅបានលុះត្រតែមានការយល់ព្រមពីរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នថ្នាក់ស្មើក្រសួង ឬ ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង បើគ្មានការយល់ព្រម ត្រូវអង្គការថ្នាក់លើផ្ទាល់ជាអ្នកសម្រេច ។

## ជំពូកទី៣

## អំពីការឃុំខ្លួនជាបណ្តោះអាសន្ន

**មាត្រា ១០** ការឃុំខ្លួនជាបណ្តោះអាសន្នអាចនឹងធ្វើទៅបាន ដោយផ្អែកលើលក្ខខ័ណ្ឌ ៣ យ៉ាងដូចខាងក្រោម ៖

១-បទល្មើសត្រូវមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងច្បាប់ ហើយដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគា ។

២-មានពិរុទ្ធភាពលើជនប្រព្រឹត្តបទល្មើស

៣-ការឃុំខ្លួនខានពុំបាន ប្រសិនបើការឃុំខ្លួនជាលក្ខណៈរ៉ាប់រងនូវការឃាត់ខ្លួនជនជាប់ចោទសម្រាប់ជូនទៅតុលាការជំនុំជម្រះបានគ្រប់ពេលវេលា ជាលក្ខណៈការពារមិនអោយជនជាប់ចោទមានសកម្មភាពបង្កអន្តរាយដល់សន្តិសុខសង្គម និងជាលក្ខណៈការពារមិនអោយជនជាប់ចោទបំផ្លាញភ័ស្តុតាង និង ឯកសារផ្សេងៗក្លែងភ័ស្តុតាង សូកសាក្សី ឬទាក់ទងជាមួយបក្សពួកខ្លួន ដើម្បីធ្វើអោយខូចប្រយោជន៍ដល់ការស៊ើបអង្កេត ។

**មាត្រា ១១** ហាមដាច់ខាតមិនអោយឃុំខ្លួន ៖

-ជនប្រព្រឹត្តបទល្មើសរដ្ឋប្បវេណី

-ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់

-ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌតូចតាច គ្មានគ្រោះថ្នាក់ដល់សង្គម

-អនីតិជនអាយុតិចជាង ១៤ ឆ្នាំ ។ ក្នុងករណីធ្ងន់ធ្ងរ និងមានការកំណត់ដោយឡែក

-ជនដែលមិនបានប្រព្រឹត្តបទល្មើស

## ជំពូកទី៤

## អំពីអង្គការមានសមត្ថកិច្ចក្នុងការចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ជាបណ្តោះអាសន្ន និង ដោះលែងជនប្រព្រឹត្តបទល្មើស

**មាត្រា ១២** ស្ថាប័ននគរបាល ស្ថាប័នសន្តិសុខកងទ័ព មានសិទ្ធិធ្វើអង្កេតស៊ើបសួរ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ជាបណ្តោះអាសន្នដោះលែងជនប្រព្រឹត្តបទល្មើស និង រៀបចំធ្វើសំណុំរឿងជូនទៅអយ្យការ ។

**មាត្រា ១៣** ស្ថាប័ននគរបាល ជាអង្គការមានសមត្ថកិច្ចក្នុងការអង្កេតស៊ើបសួរ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន និង ដោះលែងជនប្រព្រឹត្តបទល្មើស ដែលជាជនស៊ីវិល ។

**មាត្រា ១៤** ស្ថាប័នសន្តិសុខកងទ័ព អង្គការមានសមត្ថកិច្ចក្នុងការអង្កេតស៊ើបសួរ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន និង ដោះលែងជនប្រព្រឹត្តបទល្មើសដែលជាយោធិន ឬ ជាជនស៊ីវិលប្រព្រឹត្តបទល្មើសប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ព ។

**មាត្រា ១៥** ក្នុងពេលធ្វើការអង្កេតស៊ើបសួរ បើស្ថាប័ននគរបាលរកឃើញជនប្រព្រឹត្តបទល្មើសជាយោធិន ស្ថាប័ននគរបាលត្រូវពិភាក្សាជាមួយស្ថាប័នសន្តិសុខកងទ័ព ឬ ស្ថាប័នកងទ័ពមានសមត្ថកិច្ច ដើម្បីសហការការងារ ។ ក្នុងករណីចាំបាច់ ដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ស្ថាប័ននគរបាលមានសិទ្ធិចាប់ខ្លួន ឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស ហើយត្រូវរាយការណ៍ជាបន្ទាន់ទៅស្ថាប័នកងទព័មានសមត្ថកិច្ច ។

ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរគិតពីថ្ងៃចាប់ខ្លួន ស្ថាប័ននគរបាលត្រូវបញ្ជូនសំណុំរឿង វត្ថុតាងព្រមទាំងជនប្រព្រឹត្តបទល្មើសទៅស្ថាប័នកងទ័ពមានសមត្ថកិច្ច ដើម្បីបន្តការអនុវត្តអង្កេតស៊ើបសួរ និងដោះស្រាយ ។

**មាត្រា ១៦** ក្នុងពេលធ្វើការសង្កេតស៊ើបសួរបើស្ថាប័នសន្តិសុខកងទ័ព រកឃើញជនប្រព្រឹត្តបទល្មើសជាជនស៊ីវិលដែលប្រព្រឹត្តល្មើសប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ព ស្ថាប័នសន្តិសុខកងទ័ពត្រូវពិភាក្សាជាមួយស្ថាប័ននគរបាលនៅទីកន្លែង ដែលជនប្រព្រឹត្តបទល្មើសនោះស្នាក់នៅ ដើម្បីសហការការងារ ។ ក្នុងករណីចាំបាច់ដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ស្ថាប័នកងទ័ព មានសិទ្ធិចាប់ខ្លួន ឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស ហើយត្រូវរាយការជាបន្ទាន់ទៅស្ថាប័ននគរបាល ។

ក្នុងករណីរកឃើញជនប្រព្រឹត្តបទល្មើសជាជនស៊ីវិលប្រព្រឹត្តល្មើស ពុំមានប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ពទេ នោះស្ថាប័នកងទ័ពត្រូវបញ្ជូនសំណុំរឿង វត្ថុតាង ព្រមទាំងជនប្រព្រឹត្តបទល្មើសនៅស្ថាប័ននគរបាលក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរគិតពីថ្ងៃចាប់ខ្លួនដើម្បីបន្តការអង្កេតស៊ើបសួរ និងដោះស្រាយ ។

**មាត្រា ១៧** ប្រសិនបើមានបទល្មើសកើតឡើង ក្នុងកាលៈទេសៈកំពុងមានការប្រយុទ្ធ ប៉ុន្តែកម្មាភិបាលនគរបាលជាសមត្ថកិច្ចមិនមានមុខទៅទីនោះ កម្មាភិបាលកងទ័ពមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ១៨ មានសិទ្ធិចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ឬដោះលែងជនប្រព្រឹត្តបទល្មើស ។

ក្នុងរយៈពេល១០ថ្ងៃ គិតពីថ្ងៃចាប់ខ្លួន ស្ថាប័នកងទ័ពដែលចាប់ខ្លួនជនប្រព្រឹត្តបទល្មើសនោះត្រូវបញ្ជូនសំណុំរឿងវត្ថុតាង ព្រមទាំងជនប្រព្រឹត្តបទល្មើសទៅស្ថាប័ននគរបាលជាសមត្ថកិច្ចវិញ ដើម្បីដោះស្រាយ ។

**មាត្រា ១៨** កម្មាភិបាលមានសមត្ថកិច្ចដូចខាងក្រោម ទើបមានសិទ្ធចេញលិខិត ឬ ដីកា ដើម្បីចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ឬ ដោះលែងជនប្រព្រឹត្តបទល្មើស ៖

**ក-ស្ថាប័ននគរបាល ៖**

-ប្រធាននគរបាលស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង លើកលែងតែការចេញលិខិតឃុំខ្លួនជាបណ្តោះអាសន្ន ។

-នាយកមន្ទីរនគរបាលខេត្ត-ក្រុង

-ប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋាននគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយនៃក្រសួងមហាផ្ទៃ ។

-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ខ-ស្ថាប័នកងទ័ព ៖**

-ប្រធានយោធាខេត្ត-ក្រុង

-ប្រធានកងពលតូចចំណុះ ក្រសួងការពារប្រទេស

-ប្រធានកងពលធំ

-ប្រធានគណៈបញ្ជាការតំបន់

-ប្រធានស្នងការសន្តិសុខកងទ័ព

-ប្រធានអគ្គសេនាធិការ

-រដ្ឋមន្ត្រីក្រសួងការពារប្រទេស

**គ-ស្ថាប័នអយ្យការ និង តុលាការ**

-រដ្ឋអាជ្ញាអមតុលាការប្រជាជន

-រដ្ឋអាជ្ញាអមតុលាការយោធា

-តុលាការប្រជាជន

-តុលាការយោធា

**មាត្រា ១៩** ការចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ដោះលែងជនប្រព្រឹត្តបទល្មើសរបស់ប្រធាននគរបាលស្រុកទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង ត្រូវមានការយល់ព្រមពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខណ្ឌ ជាយក្រុង ។

ការចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ឬ ដោះលែងជនប្រព្រឹត្តបទល្មើសរបស់នាយកមន្ទីរនគរបាលខេត្ត-ក្រុង ត្រូវមានការយល់ព្រមពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ។

ការចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ឬ ដោះលែងជនប្រព្រឹត្តបទល្មើសរបស់ប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋាននគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយនៃក្រសួងមហាផ្ទៃ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ឬ ដោះលែងជនប្រព្រឹត្តបទល្មើសរបស់ប្រធានយោធាខេត្ត-ក្រុង ប្រធានកងពលតូចចំណុះក្រសួងការពារប្រទេស ប្រធានកងពលធំ ត្រូវមានការយល់ព្រមពីគណៈបញ្ជាការតំបន់ ឬ ស្ថាប័នកងទ័ពមានសមត្ថកិច្ច ។

ការចេញលិខិតអោយចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ឬដោះលែងជនប្រព្រឹត្តបទល្មើសរបស់គណៈបញ្ជាការតំបន់ ប្រធានស្នងការសន្តិសុខកងទ័ព ត្រូវមានការយល់ព្រមពីប្រធានអគ្គសេនាធិការ ឬ រដ្ឋមន្ត្រីក្រសួងការពារប្រទេស ។

ក្រោយពីការចាប់ខ្លួន និងឃុំខ្លួនជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែងណាមួយនោះ ស្ថាប័ននគរបាល ស្ថាប័នកងទ័ព ត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋអាជ្ញាអមតុលាការប្រជាជន ឬ រដ្ឋអាជ្ញាអមតុលាការយោធា ។

ក្នុងករណីបន្ទាន់ និងមានភ័ស្តុតាងមួយចំនួនដូចមានចែងក្នុងមាត្រា ៦ កម្មាភិបាលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ១៨ គឺមានសិទ្ធិចាប់ខ្លួនជនប្រព្រឹត្តបទល្មើសនោះភ្លាម ក្រោយពេលដែលចាប់ឃាត់ខ្លួនត្រូវរាយការណ៍ជាបន្ទាន់ជូនគណៈកម្មាធិការប្រជាជនបដិវត្តស្រុក-ខេត្ត-ក្រុង ឬ រដ្ឋមន្ត្រីជ្រាប ។

ក្នុងករណីគ្មានការយល់ព្រមពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានស្ថាប័នកងទ័ពមានសមត្ថកិច្ច ឬ រដ្ឋមន្ត្រីក្រសួងការពារប្រទេសដូចមានចែងខាងលើអាចអនុញ្ញាតអោយឃុំខ្លួនបន្ត ១ខែ ទៀតបាន ចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ ឆ្នាំ ឬ ២ ខែទៀតបាន ចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

**មាត្រា ២៦** ពោះការប្រព្រឹត្តបទល្មើសជាក់ស្ដែង បើប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋាននគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយនៃក្រសួងមហាផ្ទៃ ប្រធានគណៈ

បញ្ជាការតំបន់ ប្រធានស្នងការសន្តិសុខកងទ័ព ចាប់ខ្លួនជនប្រព្រឹត្តបទល្មើលត្រូវសួរចម្លើយជាបន្ទាន់ ។ សំណុំរឿងកំណត់ហេតុវត្ថុតាង ឬ វត្ថុតាងត្រូវជូនទៅអយ្យការខេត្ត-ក្រុង មានសមត្ថកិច្ច ឬ អយ្យការយោធា ក្នុងរយៈ១៥ថ្ងៃ យ៉ាងយូរគិតពីថ្ងៃចាប់ខ្លួន ។

ប្រសិនបើយល់ឃើញថាត្រូវឃុំខ្លួនជនប្រព្រឹត្តបទល្មើសបន្តទៅទៀត ដើម្បីធ្វើអង្កេតស៊ើបសួរនោះ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋន្ត្រីក្រសួងការពារប្រទេស ឬ ប្រធានអគ្គសេនាធិការតែ ការអនុញ្ញាតនោះមិនត្រូវអោយលើសពី ២ខែ ចំពោះបទល្មើសដែលអតិបរមានៃទាសកំណត់ក្នុងច្បាប់តិច ជាង ៥ឆ្នាំ និងមិនអោយលើសពី ៤ខែ ចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ ឆ្នាំ ។

ក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស ឬ ប្រធានអគ្គសេនាធិការ អាចអនុញ្ញាតអោយបន្តការឃុំខ្លួនជាបណ្តោះអាសន្ន ១ខែ ទៀតបានចំពោះបទល្មើសដែលអតិចរបនទោស កំណត់ក្នុងច្បាប់តិចជាង៥ឆ្នាំ ឬ ២ ខែទៀតបាន ចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់ លើសពី ៥ ឆ្នាំ ។

**មាត្រា ២៧** ក្នុងបទល្មើសដែលមិនមែនជាបទល្មើសជាក់ស្តែងការឃុំខ្លួន ដែលធ្វើអោយនគរបាល យោធាខេត្ត-ក្រុង ប្រធានកងពលតូចចំណុះក្រសួងការពារប្រទេស ប្រធានកងពលធំប្រធានគណៈ បញ្ជាការតំបន់ ប្រធានស្នងការសន្តិសុខកងទ័ព ឬ ប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋាន នគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយនៃក្រសួងមហាផ្ទៃមិនត្រូវអោយលើសពី ២ខែ ចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និងមិនត្រូវអោយលើស ៤ខែ ចំពោះបទល្មើស ដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

ក្នុងករណីចាំបាច់ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ឬ ប្រធានស្ថាប័នកងទ័ពមាន សមត្ថកិច្ចអាចអនុញ្ញាតអោយនគរបាល យោធាខេត្ត-ក្រុង ប្រធានកងពលធំ បន្តការឃុំខ្លួនជនប្រព្រឹត្តិបទ ល្មើស ១ខែ ទៀតបាន ចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និង ២ខែ ទៀតបានចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចអនុញ្ញាតអោយ ប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋា ននគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយបន្តការឃុំខ្លួនជនប្រព្រឹត្តបទល្មើស១ខែ ទៀត បានចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និង ២ខែ ទៀតបានចំពោះបទ ល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

រដ្ឋមន្ត្រីក្រសួងការពារប្រទេស ឬ ប្រធានអគ្គសេនាធិការអាចអនុញ្ញាតអោយប្រធានគណៈបញ្ជាការ តំបន់ ប្រធានស្នងការសន្តិសុខកងទ័ព បន្តការឃុំខ្លួនជនប្រព្រឹត្តបទល្មើស ១ខែ ទៀតបានចំពោះបទល្មើស ដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និង ២ខែ ទៀតបានចំពោះបទល្មើសដែលអប្បបរមា នៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

**មាត្រា ២៨** ចំពោះបទល្មើសប៉ះពាល់ដល់សន្តិសុខនយោបាយ ការឃុំខ្លួនជាបណ្តោះអាសន្នអាចមាន រយៈពេលដល់ ១២ខែបាន ។ ក្រុមប្រឹក្សា រដ្ឋប្រគល់សិទ្ធិអោយក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យ និងសម្រេចអំពី ករណីពិសេស ដែលត្រូវពន្យាការឃុំខ្លួនលើសពី ១២ខែ ។

រដ្ឋមន្ត្រីក្រសួងការពារប្រទេស បើជនល្មើសជាយោធិន ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើជនល្មើសជាជនស៊ីវិល សម្រេចអោយបន្តការឃុំខ្លួនជាបណ្តោះអាសន្នដល់ ១២ខែ ។

**មាត្រា ២៩** រដ្ឋអាជ្ញាអមតុលាការប្រជាជន និង រដ្ឋអាជ្ញាអមតុលាការយោធាមានសិទ្ធិចេញដីកាអោយចាប់ខ្លួន ឃុំខ្លួន ឬ ដោះលែង ដូចមានចែងក្នុងមាត្រា ១៨ បានចំពោះតែជនណាដែលទាក់ទងសំណុំរឿងដែលខ្លួនដោះស្រាយ ។ ការឃុំខ្លួនតាមដីកានោះមិនត្រូវអោយលើសពី ២ខែ ចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និងមិនត្រូវអោយលើសពី ៤ខែ ចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

ក្នុងករណីចាំបាច់អគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល អាចអនុញ្ញាតអោយរដ្ឋអាជ្ញាអមតុលាការប្រជាជន និង រដ្ឋអាជ្ញាអមតុលាការយោធាបន្តការឃុំខ្លួនបានចំនួន ១ខែ ចំពោះបទល្មើសដែលអតិបរមានៃទោសកំណត់ក្នុងច្បាប់តិចជាង ៥ឆ្នាំ និង ២ខែ ទៀតបាន ចំពោះបទល្មើសដែលអប្បបរមានៃទោសកំណត់ក្នុងច្បាប់លើសពី ៥ឆ្នាំ ។

តុលាការប្រជាជន និង តុលាការយោធាមានសិទ្ធិចេញសេចក្តីសម្រេចអោយចាប់ខ្លួន ឃុំខ្លួន និង ដោះលែងចំពោះតែជនណាដែលទាក់ទងនិងសំណុំរឿងដែលខ្លួនទទួលដោះស្រាយ ។

ស្ថាប័ននគរបាលមានសមត្ថកិច្ច មានករណីយកិច្ចត្រូវអនុវត្តសេចក្តីសម្រេច និង ដីការបស់រដ្ឋអាជ្ញាអមតុលាការប្រជាជន ។

តម្រួតយោធា កងពលតូចចំណុះក្រសួងការពារប្រទេស ស្នងការសន្តិសុខកងទ័ពមានករណីយកិច្ចត្រូវអនុវត្តសេចក្តីសម្រេច និង ដីការបស់រដ្ឋអាជ្ញាអមតុលាការយោធា ។

**មាត្រា ៣០** អាគារសម្រាប់ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន និង ពន្ធនាគារ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងការពារប្រទេស ក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី ។

ជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្នមិនត្រូវដាក់ឃុំជាមួយនិងទណ្ឌិតឡើយ ។ រីឯអនីតិជនក៏មិនត្រូវដាក់ឃុំជាមួយនីតិជនដែរ ។

ជនដែលឃាត់ខ្លួន ឬ ឃុំខ្លួន ត្រូវបានទទួលរបបតាមការកំណត់របស់រដ្ឋ ។

**មាត្រា ៣១** សិទ្ធិមិនអោយមានការរំលោភបំពានលើរូបកាយជនដែលត្រូវឃុំខ្លួនត្រូវបានរដ្ឋធានា ។

ជនដែលត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន អាចទាក់ទងជាមួយអ្នកការពាររបស់ខ្លួនបានដោយពុំត្រូវមានវត្តមានតតិយជនណាមួយឡើយ ។ អ្នកការពារអាចទាក់ទងជាមួយជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្នបានលុះត្រាតែមានការអនុញ្ញាតពីប្រធានតុលាការ ជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្នអាចទាក់ទងជាមួយគ្រួសារ ឬ សាច់ញាតិរបស់ខ្លួនបានតាមរបបកំណត់របស់ពន្ធនាគារ ។

តំណាងអយ្យការ និង តុលាការមានសិទ្ធិសួរយកចម្លើយពីជនជាប់ឃុំឃាំងជាបណ្តោះអាសន្នបានក្រោយពីបានទទួលសំណុំរឿងក្នុងករណីនេះនគរបាល និងអ្នកទទួលខុសត្រូវនៃពន្ធនាគារត្រូវបង្កលក្ខណៈងាយស្រួលដល់ការសួរយកចម្លើយនេះ ។

**មាត្រា ៣២** បើមានការឃុំខ្លួនជនប្រព្រឹត្តបទល្មើស ត្រូវអោយដំណឹងទៅសាច់ញាតិនៃជននេះ ជូនដំណឹងទៅអង្គភាពនៃទីកន្លែងដែលជនប្រព្រឹត្តបទល្មើសកំពុងធ្វើការ ឬ គណៈកម្មាធិការប្រជាជនបដិវត្ត ឃុំ សង្កាត់ នៃទីលំនៅរបស់ជនដែលត្រូវឃុំជាបណ្តោះអាសន្ននោះ ។ ប្រសិនបើការអោយដំណឹងបណ្តាលឲ្យមានការរាំងស្ទះដល់ការស៊ើបអង្កេតនោះត្រូវអោយដំណឹងក្រោយពេលអង្កេតស៊ើបសួររួច ។

**មាត្រា ៣៣** ជនដែលត្រូវបានដោះលែងជាស្ថាពរ ឬ ដោះលែងអោយនៅក្រៅឃុំជាបណ្តោះអាសន្ន មានសិទ្ធិទទួលមកវិញនូវទ្រព្យសម្បត្តិដែលពុំមែនជាវត្ថុតាងនៃបទល្មើស ឬ ពុំមែនជាទ្រព្យសម្បត្តិដែលរដ្ឋតម្រូវអោយរឹបអូស ។

ជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ក្រោយពេលស្រាវជ្រាវ បើឃើញថាគ្មានកំហុស ត្រូវបានទទួលសិទ្ធិសេរីភាពវិញ ព្រមទាំងអត្ថប្រយោជន៍ខាងវិស័យនយោបាយ សេដ្ឋកិច្ច ការរស់នៅ និងពលកម្មដូចដើមវិញ ។

## ជំពូកទី៥

## អំពីការឆែកឆេរលំនៅដ្ឋានឆែកឆេរសម្ភារ វត្ថុ និង លើខ្លួនបុគ្គល

**មាត្រា ៣៤** ការឆែកឆេរលំនៅដ្ឋាននឹងអាចធ្វើទៅបាន បើមានការចាំបាច់ក្នុងការស្វែងរកភ័ស្តុតាងនៃពិរុទ្ធភាព ឬ បើមាននិមិត្តហេតុអោយសន្មតបានថាម្ចាស់ផ្ទះ ឬ ញាតិមិត្តរបស់ម្ចាស់ផ្ទះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ។

**មាត្រា ៣៥** ការឆែកឆេរលំនៅដ្ឋាននឹងអាចធ្វើទៅបានលុះត្រាតែមានលិខិតបង្គាប់ការ ឬ ដីកាពី ៖

-ប្រធាននគរបាលស្រុក ស្រុកជាយក្រុង ដោយមានករយល់ព្រមពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ស្រុកជាយក្រុង ។

-ប្រធាននគរបាលខេត្ត-ក្រុង ដោយមានការយល់ព្រមពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ។

-ប្រធាននាយកដ្ឋានសន្តិសុខប្រជាជន ប្រធាននាយកដ្ឋាននគរបាលប្រជាជន ប្រធាននាយកដ្ឋានស្រាវជ្រាវសួរចម្លើយ ក្រសួងមហាផ្ទៃ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

-រដ្ឋអាជ្ញាអមតុលាការប្រជាជនខេត្ត-ក្រុង ។

**មាត្រា ៣៦** ម្ចាស់ផ្ទះ ឬ តំណាងម្ចាស់ផ្ទះ មានសិទ្ធិចូលរួមក្នុងការឆែកឆេរលំនៅដ្ឋានរបស់ខ្លួន ហើយការឆែកឆេរអាចនឹងប្រព្រឹត្តទៅបាន លុះត្រាតែមានសាក្សីយ៉ាងតិច ២នាក់ចូលរួមផង។ ក្នុងសាក្សី ២ នាក់នេះ ត្រូវជ្រើសរើសម្នាក់ក្នុងបណ្តាគណៈកម្មាធិការប្រជាជនបដិវត្តនៅទីនោះ ។

**មាត្រា ៣៧** នគរបាលអាចចូលទៅក្នុងលំនៅដ្ឋានរបស់អ្នកដទៃបាន ដោយមិនចាំបាច់តម្រូវអោយមានដីកាពីរដ្ឋអាជ្ញា ឬ លិខិតបង្គាប់ការពីអង្គការមានសមត្ថកិច្ច និង មិនចាំបាច់មានសាក្សីទេ ប្រសិនបើមានការចាំបាច់ក្នុងការចាប់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែងឬបើមានការស្រែកហៅអោយជួយពីក្នុងផ្ទះ ។

**មាត្រា ៣៨** ក្នុងករណីណាក៏ដោយ អង្គការមានសមត្ថកិច្ចឆែកឆេរ ត្រូវធ្វើកំណត់ហេតុច្បាស់លាស់ជា ២ ច្បាប់នៅនឹងកន្លែង ដោយមានចុះហត្ថលេខាភ្នាក់ងារទទួលខុសត្រូវ ម្ចាស់ផ្ទះ ឬ តំណាងម្ចាស់ផ្ទះ និងសាក្សី ។កំណត់ហេតុ ១ ច្បាប់ ត្រូវប្រគល់អោយម្ចាស់ផ្ទះ ឬ អ្នកតំណាងម្ចាស់ផ្ទះ ១ ច្បាប់ទៀត ត្រូវអាជ្ញាធរសាធារណៈដែលធ្វើការឆែកឆេររក្សាទុក ។

អង្គការមានសមត្ថកិច្ចឆែកឆេរ អាចរឹបអូសសម្ភារ វត្ថុ នានាជាបណ្តោះអាសន្នដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការរកការពិត ហើយត្រូវកត់ត្រាអោយបានច្បាស់លាស់ក្នុងកំណត់ហេតុ នូវសម្ភារ វត្ថុដែលរឹបអូសជាបណ្តោះអាសន្ននោះ

ចំពោះឯកសារដែលជាវត្ថុតាង ត្រូវអោយម្ចាស់ផ្ទះ ឬ តំណាងម្ចាស់ផ្ទះចុះហត្ថលេខា បញ្ជាក់លើឯកសារទាំងនោះ ។

ទ្រព្យសម្បត្តិដែលរឹបអូសជាបណ្តោះអាសន្ន ហើយដែលជារូបិយវត្ថុ មាស ពេជ្រ ត្បូង មានតម្លៃត្រូវដាក់ក្នុងហិបចាក់សោបិតស្លាក ចុះហត្ថលេខា បោះត្រា ហើយត្រូវយកទៅតម្កល់ទុកនៅធនាគារជាបន្ទាន់ ។

ម្ចាស់ផ្ទះមានសិទ្ធិជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិខាងលើវិញ កាលបើមានសេចក្តីបង្គាប់អោយរំលាយចោលនូវបញ្ជាដែលអោយកត់ និង រឹបអូសជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិនោះ។

**មាត្រា ៣៩** ការឆែកឆេរលំនៅដ្ឋានធ្វើបានតែពីម៉ោង ៦ ព្រឹក ទៅ ម៉ោង ៦ ល្ងាច ។ ហាមផ្តាច់មិនអោយធ្វើការឆែកឆេរលំនៅដ្ឋានក្រៅពីពេលខាងលើនេះ លើកលែងតក្នុងករណីដែលមានចែងក្នុងមាត្រា ៣៧ និងក្នុងករណីធ្ងន់ធ្ងរពិសេស និងជាបន្ទាន់ប៉ះពាល់ដល់សន្តិសុខជាតិ ។

**មាត្រា ៤០** អាជ្ញាធរយោធាគ្មានសិទ្ធិធ្វើការឆែកឆេរលំនៅដ្ឋានរបស់ជនស៊ីវិលបានទេ លើកលែងតែការប្រព្រឹត្តបទល្មើសនោះប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ព។ ក្នុងករណីខាងក្រោយនេះត្រូវមានលិខិតបង្គាប់ការពីរអាជ្ញាធរយោធា ទទួលបន្ទុកការស៊ើបអង្កេត ។

**មាត្រា ៤១** ដើម្បីធ្វើការស្វែងរកសម្ភារ វត្ថុ ណាមួយដែលជាភ័ស្តុតាងនៃបទបទល្មើស ហើយដោយបានទទួលលិខិត ឬ ដីកាបង្គាប់ពីអាជ្ញាធរមានសមត្ថកិច្ច អង្គការមានសមត្ថកិច្ចក្នុងការឆែកឆេរអាចធ្វើការឆែកឆេរសម្ភារ វត្ថុ ឬ លើខ្លួនជនទាំងឡាយណាដែលគេអាចប៉ាន់ស្មានដោយពេញច្បាប់ថា ជននោះមានលាក់ទុកនៅនឹងខ្លួននូវវត្ថុដែលត្រូវស្វែងរក ។

ក្នុងការឆែកឆេរបើជនល្មើសជានារីភេទ ត្រូវធ្វើការឆែកឆេរនៅទីកំបាំង ហើយត្រូវធ្វើដោយភ្នាក់ងារជានារីដូចគ្នា ។

**មាត្រា ៤២** សម្ភារ វត្ថុ ដែលត្រូវរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើមានត្រូវចុះក្នុងកំណត់ហេតុមានចុះហត្ថលេខារបស់អាជ្ញាធរ ដែលធ្វើកំណត់ហតុនិងម្ចាស់សម្ភារ វត្ថុ ហើយបញ្ជូនជាបន្ទាន់ទៅអង្គការមានសមត្ថកិច្ចដើម្បីសម្រេច កំណត់ហេតុត្រូវធ្វើអោយបានច្បាស់លាស់ជា ២ ច្បាប់ ១ ច្បាប់ ត្រូវប្រគល់ឲ្យទៅម្ចាស់សម្ភារ វត្ថុ ១ច្បាប់ទៀតត្រូវអាជ្ញាធរសាធារណៈដែលធ្វើការឆែកឆេរនោះរក្សាទុក ។

**មាត្រា ៤៣** ការរឹបអូសទ្រព្យសម្បត្តិរបស់ពលរដ្ឋដោយរំលោភ ត្រូវហាមឃាត់ដាច់ខាត ។

## **ជំពូកទី៦**

## **ទោសប្បញ្ញត្តិ**

**មាត្រា ៤៤** ជនណាចាប់ ឃាត់ ឬ ឃុំខ្លួន ឆែកឆេរលំនៅដ្ឋាន សម្ភារ វត្ថុ ឬ លើខ្លួនបុគ្គល មិនស្របនឹងបទបញ្ញត្តិនៃក្រឹត្យ-ច្បាប់នេះ ត្រូវផ្តន្ទាទោសរដ្ឋបាល និង ទទួលខុសត្រូវចេញសំណងជួសជុលការអន្តរាយដែលខ្លួនបានបង្កឡើង ។ ប្រសិនបើមានលក្ខណៈធ្ងន់ធ្ងរ ត្រូវផ្តន្ទន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៤៥** ជនណាបង្កឧបសគ្គដល់ការអនុវត្តន៍ អាជ្ញាចាប់ឃាត់ ឬ ឃុំខ្លួន ក្នុងគោលបំណងបិទបាំងជនប្រព្រឹត្តបទល្មើស ក្នុងគោលបំណងចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន បង្កអន្តរាយដល់ការស៊ើបអង្កេត ឬ មិនព្រមដោះលែងតាមលិខិត ដីការបស់អង្គការមានសមត្ថកិច្ច ឬកំណត់នៃសាលក្រមរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនគារពី ៣ ខែ ដល់ ២ ឆ្នាំ ។

**មាត្រា ៤៦** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ដល់ ៣ឆ្នាំ ចំពោះ ៖

-ជនណាដែលគ្មានសិទ្ធិចេញអាជ្ញាចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ជនណាដែលគ្មានបានទទួលបង្គាប់ជាលាយលក្ខណ៍អក្សរពីអង្គការមានសមត្ថកិច្ច និង ក្រៅពីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ហើយបានចាប់ខ្លួនឃាត់ខ្លួន ឬ ឃុំខ្លួន បុគ្គលណាមួយដោយរំលោភ ។

-ជនណា ដែលបានធ្វើទារុណកម្មលើខ្លួនបុគ្គល ដែលត្រូវចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ។

-កម្មាភិបាលសួរចម្លើយណា ដែលធ្វើទារុណកម្មលើខ្លួនបុគ្គលក្នុងការសួរចម្លើយ ។ បើអំពើរំលោភណាមួយខាងលើ ចូលជាបទល្មើសព្រហ្មទណ្ឌ ដែលមានកំណត់ក្នុងច្បាប់ជាធរមាននោះ ជនប្រព្រឹត្តបទល្មើសនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាននេះ ។

**មាត្រា ៤៧** ជនណាប្រឌិតភ័ស្តុតាងដើម្បីចេញអាជ្ញាចាប់ ឃាត់ ឬ ឃុំខ្លួនជនស្លូតត្រង់ក្នុងគោលបំណងបង្អាប់កិត្តិយស ឬ សងសឹកនោះត្រូវផ្តន្ទាទោសពី ៦ខែ ដល់ ៧ឆ្នាំ ។

-ករណីធ្ងន់ធ្ងរត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៤៨** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ៧ឆ្នាំ ចំពោះ ៖

-ជនណាដែលបានរឹបអូសយកទ្រព្យសម្បត្តិរបស់ពលរដ្ឋដោយរំលោភ ក្នុងការឆែកឆេរលំនៅដ្ឋាន សម្ភារ វត្ថុ ឬ លើខ្លួនបុគ្គល ។

-កម្មាភិបាលដែលមានភារកិច្ចរឹបអូសជាបណ្តោះអាសន្នថែរក្សា គ្រប់គ្រង វត្ថុតាង សម្ភារ វត្ថុ កត់ត្រាទ្រព្យសម្បត្តិ ដែលផ្លាស់ប្តូរក្លែងបន្លំ តែបំបាត់ទ្រព្យសម្បត្តិនោះ ។

## ជំពូកទី៧

## បទបញ្ញត្តិជាអវសាន

**មាត្រា ៤៩** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទបញ្ញត្តិនៃក្រឹត្យ-ច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥០** ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យ-ច្បាប់នេះ ។

**មាត្រា ៥១** ក្រឹត្យ-ច្បាប់នេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៦

| | |
|---|---|
| ទទួលបន្ទុកអនុវត្ត | ជ.ក្រុមប្រឹក្សារដ្ឋ |
| ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី | ប្រធាន |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **ហ៊ុន សែន** | **ហេង សំរិន** |